# កំណត់សំគាល់ ផ្នែកច្បាប់
# ស្តីពី
# ការអនុវត្តភាតព្វកិច្ចតាមច្បាប់ស្តីពី គណនេយ្យ និងសវនកម្ម
# ដោយអង្គភាពមិនស្វែងរកប្រាក់ចំណេញឬ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល( NGOs )

---

## ប្រវត្តិ

ព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១៦ ប្រកាសឲ្យប្រើច្បាប់ ស្តីពី គណនេយ្យ និងសវនកម្ម ។

ច្បាប់នេះមានគោលដៅ ៖

- កំណត់ក្របខ័ណ្ឌគតិយុត្តិសម្រាប់ការគ្រប់គ្រង គណនេយ្យ និងសវនកម្ម
- ពង្រឹង និងអភិវឌ្ឍសមត្ថភាពស្ថាប័ន សម្រាប់ការគ្រប់គ្រងគណនេយ្យ និងសវនកម្ម
- ពង្រឹង និងអភិវឌ្ឍសមត្ថភាពជំនាញ និងការទទួលខុសត្រូវរបស់គណនេយ្យករ និងសវនករ ។
- កំណត់ក្របខ័ណ្ឌគតិយុត្តិសម្រាប់ការដាក់អោយអនុវត្ត ស្តង់ដាគណនេយ្យ ស្តង់ដាសវនកម្ម និងក្រមសីលធម៌វិជ្ជាជីវរបស់គណនេយ្យករ និងសវនករ ដែលជាគោលការត្រូវមានសង្គតិភាពជាមួយស្តង់ដាអន្តរជាតិ និងត្រូវឆ្លុះបញ្ចាំងសេចក្តីត្រូវការជាក់ស្តែង របស់កម្ពុជា ។
- ដាក់ចេញនូវយន្តការវិធាន និងនីតិវិធីសម្រាប់ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ លើការអនុវត្តច្បាប់នេះ ។
- ពង្រឹងនិងអភិវឌ្ឍវិជ្ជាជីវៈ គណនេយ្យ និងសវនកម្ម នៅព្រះរាជាណាចក្រកម្ពុជា ។[1]

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះ ស្ថាប័នសាធារណៈ សហគ្រាស អង្គភាពមិនស្វែងរកប្រាក់ចំណេញ គណនេយ្យករ និងសវនករ ។

ច្បាប់នេះមិនអនុវត្តចំពោះ ធនាគារកណ្តាល និងចំពោះតួនាទីនិងភារកិច្ច ដែលជាសមត្ថកិច្ចរបស់អាជ្ញាធរសវនកម្មជាតិទេ។[2]

---

[1] មាត្រា ២ នៃច្បាប់ ស្តីពី គណនេយ្យ និងសវនកម្ម

[2] មាត្រា ៣ នៃច្បាប់ ស្តីពី គណនេយ្យ និងសវនកម្ម

ច្បាប់ស្តីពី គណនេយ្យនិងសវនកម្ម បានបង្កើត ក្រុមប្រឹក្សាជាតិគណនេយ្យ ដែលសរសេរអក្សរកាត់ថា (គ.ជ.គ) ស្ថិតក្រោមការដឹកនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ សមាសភាពរបស់ (គ.ជ.គ) មានអាណត្តិកំណត់រយៈពេល ០៥ (ប្រាំ)ឆ្នាំ និងអាចត្រូវបានដកហូត ឬផ្លាស់ប្តូរភារកិច្ចនៅមុនពេលផុតអាណត្តិទៅតាមការចាំបាច់នៃមុខងារ។ សមាសភាពរបស់ (គ.ជ.គ) អាចបន្តអាណត្តិសាជាថ្មីបានតាមសំណើររបស់ប្រធាន (គ.ជ.គ)។[3]

ព្រះរាជក្រមលេខ នស/រកម ០១២១/០០៣ ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០២១ ប្រកាសឲ្យប្រើច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគា (អសហ) បានបង្កើតអោយមានអង្គភាពក្រោមឱវាទជាសេនាធិការដូចខាងក្រោម៖

- អគ្គលេខាធិការដ្ឋាន
- និយ័តករធានារ៉ាប់រងកម្ពុជា
- និយ័តករមូលបត្រកម្ពុជា
- និយ័តករសន្តិសុខសង្គម
- និយ័តករបរធនបាលកិច្ច
- និយ័តករគណនេយ្យ និង សវនកម្ម
- និយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ
- អង្គភាពសវនកម្មផ្ទៃក្នុង ។[4]

ក្រុមប្រឹក្សាជាតិគណនេយ្យ ត្រូវបានប្រែក្លាយទៅជា និយ័តករគណនេយ្យនិងសវនកម្ម នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របតាមបញ្ញត្តិនៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អសហ) ។

និយ័តករគណនេយ្យនិងសវនកម្ម នឹងបន្តអនុវត្តមុខងារភារកិច្ច របស់ក្រុមប្រឹក្សាជាតិគណនេយ្យ ដែលបានកំណត់នៅក្នុងច្បាប់ស្តីពី គណនេយ្យនិងសវនកម្ម និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។[5]

ក្នុងដំណាក់កាលនៃការរៀបចំលិខិតបទដ្ឋានគតិយុត្ត សម្រាប់ដំណើរការផ្លូវការរបស់ស្ថាប័ននិយ័តករគណនេយ្យនិងសវនកម្ម នឹងប្រើនិមិត្តសញ្ញា(LOGO)និងត្រារបស់ក្រុមប្រឹក្សាជាតិគណនេយ្យ នៅក្នុងលិខិតស្នាមនិងឯកសារនានា ក្នុងទំនាក់ទំនងការងារផ្លូវការ រហូតដល់និយ័តករ

[3] មាត្រា ៥ នៃច្បាប់ ស្តីពី គណនេយ្យ និងសវនកម្ម

[4] មាត្រា ១១ ច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគា (អសហ)

[5] មាត្រា ២១ ច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគា (អសហ)

មាននិមិត្តសញ្ញា(Logo) និងត្រារបស់ខ្លួនផ្ទាល់។
បេសកកម្មរបស់ និយ័តករគណនេយ្យនិងសវនកម្ម (ន.គ.ស.)គឺបំពេញមុខងារជាសេនាធិការ ឱ្យអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ(អសហ) ក្នុងការគ្រប់គ្រងនិងអភិវឌ្ឍវិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្មនៅកម្ពុជា តាមរយៈការដាក់ចេញនូវបទប្បញ្ញត្តិ វិធាននិងស្តង់ដា ព្រមទាំងជំរុញការអនុវត្តច្បាប់និងស្តង់ដាគណនេយ្យនិងសវនកម្មកម្ពុជា។

ច្បាប់ស្តីពី គណនេយ្យ និងសវនកម្ម ឆ្នាំ ២០១៦ និងច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អសហ) ព្រមទាំងលិខិតបទដ្ឋានពាក់ព័ន្ធនានា ជាពិសេស សេចក្តីណែនាំរបស់ និយ័តករគណនេយ្យ និងសវនកម្ម លេខ ០១០ ន.គ.ស ចុះថ្ងៃទី ១៥ ខែមីនា ឆ្នាំ ២០២២ ស្តីពី ការអនុវត្តកាតព្វកិច្ចគណនេយ្យ និងសវនកម្ម សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ បានបង្ហាញថា អង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល (NGOs) ត្រូវបំពេញកាតព្វកិច្ចតាមច្បាប់ជាធរមាន ។

## កាតព្វកិច្ចអនុវត្តតាមច្បាប់ សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ NGOs

១. អង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវកាន់កាប់បញ្ជីគណនេយ្យ និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុអោយបានត្រឹមត្រូវ ស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជា និងស្របតាមប្រកាសលេខ ៣៣៥ សហវ/ប្រក របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះថ្ងៃទី ២៧ ខែមីនា ឆ្នាំ ២០១៨ ស្តីពី ការដាក់អោយអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ។

ករណីអង្គភាពមិនស្វែងរកប្រាក់ចំណេញ អនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាឬស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនមក និយ័តករគណនេយ្យនិងសវនកម្ម (ន.គ.ស.) ។[6]

២. អង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមក (ន.គ.ស.) តាមពេលកំណត់ដូចខាងក្រោម ៖

២.១. អង្គភាពមិនស្វែងរកប្រាក់ចំណេញ ដែលរងសវនកម្មឯករាជតាមច្បាប់ ត្រូវបញ្ជូនរបាយការណ៍ហិរញ្ញវត្ថុ រងសវនកម្មឯករាជ្យរួច មក(ន.គ.ស.) ក្នុងអំឡុងពេល ០៦ ខែ ១៥ ថ្ងៃ ក្រោយកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ ។

២.២.អង្គភាពមិនស្វែងរកប្រាក់ចំណេញ ដែលមិនរងសវនកម្មឯករាជតាមច្បាប់ ត្រូវដាក់របាយ

[6] សេចក្តីណែនាំលេខ ០១០ ន.គ.ស ស្តីពី ការអនុវត្តកាតព្វកិច្ចគណនេយ្យ និងសវនកម្មសម្រាប់ NGOs

ការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ក្នុងអំឡុងពេល ០៣ ខែ ១៥ ថ្ងៃ ក្រោយកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ ។[7]

៣. អង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវស្នើសុំការអនុញ្ញាត្តិពី(ន.គ.ស.) លើការកំណត់យកថ្ងៃបិទបញ្ជីគណនេយ្យខុសពីថ្ងៃទី ៣១ ខែធ្នូ ។ ការស្នើសុំនេះត្រូវធ្វើអោយបានមុនថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០២២ សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ ដែលបានបង្កើតមុនថ្ងៃជូនដំណឹងនេះ ។ ចំពោះអង្គភាពមិនស្វែងរកប្រាក់ចំណេញថ្មី បង្កើតឡើងក្រោយសេចក្តីណែនាំនេះ ត្រូវស្នើសុំមក(ន.គ.ស.) ក្នុងរយៈពេល ០៣ ខែ គិតចាប់ពីថ្ងៃចុះបញ្ជីជាស្ថាពរ ជាមួយស្ថាប័នមានសមត្ថកិច្ច។[8]

៤. អង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវជូនដំណឹងមក(ន.គ.ស.) អំពីភាសាដែលបានប្រើនៅក្នុងប្រព័ន្ធគណនេយ្យកុំព្យូទ័រ ឬប្រព័ន្ធកុំព្យូទ័រពាក់ព័ន្ធ បើអង្គភាពមិនស្វែងរកប្រាក់ចំណេញស្ថិតក្នុងលកខណ្ឌដែលបានកំណត់ក្នុងសារាចរលេខ ០០៩ សហវ ចុះថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីការប្រើប្រាស់ភាសា និងរូបិយប័ណ្ណក្នុងបញ្ជីគណនេយ្យ និងរបាយការហិរញ្ញវត្ថុ ។

អង្គភាពមិនស្វែងរកប្រាក់ចំណេញ ដែលបានចុះបញ្ជីជាផ្លូវការរួចហើយ ត្រូវជូនដំណឹងពីការប្រើប្រាស់ភាសាអង់គ្លេស ក្នុងប្រព័ន្ធគណនេយ្យកុំព្យូទ័រ និង/ឬ ប្រព័ន្ធកុំព្យូទ័រពាក់ព័ន្ធផ្សេងទៀត មក (ន.គ.ស.) ចាប់ពីថ្ងៃចេញសេចក្តីណែនាំនេះរហូតដល់ថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០២២ ជាកំហិត។

សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញទើបបង្កើតថ្មី ត្រូវជូនដំណឹងពីការប្រើប្រាស់ភាសាអង់គ្លេសក្នុងប្រព័ន្ធគណនេយ្យកុំព្យូទ័រ និង/ឬ ប្រព័ន្ធកុំព្យូទ័រពាក់ព័ន្ធផ្សេងទៀតមក(ន.គ.ស.) មិនអោយហួសរយៈពេល ៦០ (ហុកសិប) ថ្ងៃ គិតចាប់ពីថ្ងៃចុះបញ្ជីជាស្ថាពរជាមួយស្ថាប័នមានសមត្ថកិច្ច។[9]

៥. អង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវប្រើប្រព័ន្ធអនឡាញ(E-Filling System) របស់(ន.គ.ស.)ដើម្បីដាក់បញ្ជូនរបាយការហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ខ្លួនមក (ន.គ.ស.) និងត្រូវបង់កម្រៃសេវាសាធារណៈសម្រាប់ការទទួលរក្សាទុករបាយការហិរញ្ញវត្ថុ ស្របតាមប្រកាសលេខ ០០១ អ.ស.ហ.ប្រ.ក ចុះថ្ងៃទី ១២ ខែមករា ឆ្នាំ ២០២២ ស្តីពីសេវាសាធារណៈរបស់និយ័តការគណនេយ្យ និងសវនកម្ម (ន.គ.ស.)។

ការខកខាន ឬការយឺតយ៉ាវមិនបានអនុវត្តកាតព្វកិច្ច តាមការកំណត់ខាងលើ អង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវរងទោសទណ្ឌដូចមានចែងក្នុងអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី០១ខែមិថុនា ឆ្នាំ ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនិងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម។[10]

៦. កំណត់ចំណាំ និងទំនាក់ទំនងជាមួយ(.ស.គ.ន)

- (ន.គ.ស.) នឹងចុះពិនិត្យដល់ទីស្នាក់ការ ឬការិយាល័យរបស់អង្គភាពក្នុងករណីចាំបាច់។

---

[7] សេចក្តីណែនាំលេខ ០១០ ន.គ.ស ស្តីពី ការអនុវត្តកាតព្វកិច្ចគណនេយ្យ និងសវនកម្មសម្រាប់ NGOs

[8] សេចក្តីណែនាំលេខ ០១០ ន.គ.ស ស្តីពី ការអនុវត្តកាតព្វកិច្ចគណនេយ្យ និងសវនកម្មសម្រាប់ NGOs

[9] សេចក្តីណែនាំលេខ ០១០ ន.គ.ស ស្តីពី ការអនុវត្តកាតព្វកិច្ចគណនេយ្យ និងសវនកម្មសម្រាប់ NGOs

[10] សេចក្តីណែនាំលេខ ០១០ ន.គ.ស ស្តីពី ការអនុវត្តកាតព្វកិច្ចគណនេយ្យ និងសវនកម្មសម្រាប់ NGOs

- ពត៌មានបន្ថែមសូមទាក់ទងមន្ត្រី (ន.គ.ស.) តាមរយៈលេខទូរស័ព្ទនិង តេឡេក្រាម ៖

០៨១ ៦៩៨ ៦៦៣០៨៩ ៥០៨ ៥៦៧ /០៧៧ ៩៦៨ ៣៩៦ /០៨៥ ៩៩៩ ៩៨៨ / ។

- អាសយដ្ឋាន: ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

- អ៊ីម៉ែល: info@naccambodia.gov.kh

- គេហទំព័រ: https://www.acar.gov.kh

## សេចក្តីសន្និដ្ឋាន

ច្បាប់ស្តីពី គណនេយ្យ និងសវនកម្ម ឆ្នាំ ២០១៦បានបង្កើតស្ថាប័នក្រុមប្រឹក្សាជាតិគណនេយ្យ (ក.ជ.គ)និងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អសហ) ឆ្នាំ ២០២១ បានបង្កើតស្ថាប័ន និយ័តករគណនេយ្យ និងសវនកម្ម (ន.គ.ស.) ។

ក្រុមប្រឹក្សាជាតិគណនេយ្យ ត្រូវបានប្រែក្លាយទៅជា និយ័តករគណនេយ្យ និងសវនកម្ម នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របតាមបញ្ញត្តិនៃច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អសហ) ។

ការងារ ឬលិខិតបទដ្ឋានគតិយុត្តិដែល ក្រុមប្រឹក្សាជាតិគណនេយ្យ បានធ្វើកន្លងមក ភាគច្រើនជាការជូនដំណឹង តម្រង់ទិស រំលឹកកាតព្វកិច្ចនានាតាមច្បាប់ ដែលអង្គភាពមិនស្វែងរកប្រាក់ចំណេញត្រូវអនុវត្ត ។

ចាប់ពីឆ្នាំ ២០២១ និយ័តករគណនេយ្យ និងសវនកម្ម បានចាប់ផ្តើមបន្តការងារពី ក្រុមប្រឹក្សាជាតិគណនេយ្យ និងបានបន្តជំរុញ និងក្រើនរំលឹកអោយអង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួនតាមច្បាប់ជាធរមាន បើមិនអនុវត្តទេអាចនិងត្រូវរងទោសទណ្ឌដូចមានចែងក្នុងអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី ០១ ខែមិថុនា ឆ្នាំ ២០២០ ស្តីពី ពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនិងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ។

អង្គភាពមិនស្វែងរកប្រាក់ចំណេញត្រូវៈ

-កាន់កាប់បញ្ជីគណនេយ្យនិងរៀបចំរបាយការណ៍ហិរញ្ញវត្ថុអោយបានត្រឹមត្រូវ ស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជា ។

-ដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំទៅ (ន.គ.ស.)

-ស្នើសុំការអនុញ្ញាត្តិពី (ន.គ.ស.) លើការកំណត់យកថ្ងៃបិទបញ្ជីគណនេយ្យខុសពីថ្ងៃទី ៣១ ខែធ្នូ

-ជូនដំណឹងមក (ន.គ.ស.) អំពីភាសាដែលបានប្រើនៅក្នុងប្រព័ន្ធគណនេយ្យកុំព្យូទ័រ ឬប្រព័ន្ធកុំព្យូទ័រពាក់ព័ន្ធ ។

-ប្រើប្រព័ន្ធអនឡាញ (E-Filling System) របស់ (ន.គ.ស.) ដើម្បីដាក់បញ្ជូនរបាយការហិរញ្ញវត្ថុ

ប្រចាំឆ្នាំរបស់ខ្លួនមក (ន.គ.ស.) ។

-កាតព្វកិច្ចផ្សេងទៀត ដែលកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច

អង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវចាប់ផ្តើមការងារអនុវត្តកាតព្វកិច្ចតាមច្បាប់របស់ខ្លួន ជាមួយ និយ័តករគណនេយ្យ និងសវនកម្ម (ន.គ.ស.) ដើម្បីជៀសវាងរងទោសទណ្ឌនិងពិន័យអន្តរការណ៍។

អង្គភាពមិនស្វែងរកប្រាក់ចំណេញ ក៏ត្រូវសហការ ពិគ្រោះយោបល់ និងតស៊ូមតិផងដែរ ជាមួយភាគីពាក់ព័ន្ធ ដើម្បីដោះស្រាយ សម្របសម្រួល បញ្ហាប្រឈមដែលមិនអាចអនុវត្តកាតព្វកិច្ច ឬមិនទាន់បានត្រៀមខ្លួនទុកជាមុខ ឬមិនទាន់បានដឹងពត៌មានសព្វគ្រប់ជ្រុងជ្រោយ ។

## សេចក្តីបញ្ជាក់

អត្ថបទបង្ហាញនេះ បានធ្វើឡើងដោយមានការឧបត្ថម្ភសប្បុរសធម៌ពីប្រជាពលរដ្ឋអាមេរិក តាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID)។ មាតិកានៃបទបង្ហាញនេះជាការទទួលខុសត្រូវរបស់អង្គការ ជំនួយ ផ្នែកច្បាប់ នៃកម្ពុជា និងមិនឆ្លុះបញ្ចាំងជាចាំបាច់ពីទស្សនៈរបស់ FHI 360 ឬ USAID ឬរដ្ឋាភិបាលសហរដ្ឋអាមេរិកឡើយ។